# តារាងបង់ថ្លៃសិក្សា ២០១១-១២

## ១. សំរាប់សិស្សថ្មី

**ក. ប្រាក់តំកល់ចុះឈ្មោះចូលរៀន:** ប្រាក់តំកល់ចំនួន៧៥០ដុល្លាសហរដ្ឋអាមេរិកត្រូវបង់នៅពេលអនុញ្ញាតអោយចូលរៀន។ ទឹកប្រាក់នេះមិនសង និងមិនអាចផ្ទេរបានទេ ប្រសិនបើសិស្សដែលបានចុះឈ្មោះមិនមកចូលរៀន។ ប្រាក់តំកល់នេះនឹងយកមកទូទាត់វិញជាមួយនឹងថ្លៃបង្រៀនដែលត្រូវបង់នៅលើកទីមួយ ។

**ខ. ថ្លៃចូលរៀន:** ទឹកប្រាក់ចំនួន២៥០០ដុល្លាសហរដ្ឋអាមេរិកត្រូវបង់ទុកជាមុននូវថ្លៃចូលរៀនសំរាប់សិស្សានុសិស្សទាំងឡាយដែលចុះឈ្មោះចូលរៀនចាប់ពីថ្នាក់ក្រោយមត្តេយ្យ (PYR) ដល់ថ្នាក់ទី១២ ទឹកប្រាក់នេះត្រូវបង់តែមួយដងគត់នៅពេលចុះឈ្មោះចូលរៀននៅលើកដំបូងប៉ុណ្ណោះ ហើយមិនសង និងមិនអាចផ្ទេរបានទេ។ សំរាប់សិស្សានុសិស្សដែលអនុញ្ញាតអោយចូលរៀនថ្នាក់មតេយ្យទី១ និងមត្តេយ្យទី២ ត្រូវបង់ថ្លៃចូលរៀនចំនួន៥០០ដុល្លាសហរដ្ឋអាមេរិកប្រាក់ថ្លៃចូលរៀនដែលបានបង់នេះនឹងត្រូវធ្វើការទូទាត់ចេញពីថ្លៃចូលរៀនសរុប ប្រសិនបើសិស្សនៅបន្តរៀនរហូតដល់ថ្នាក់ក្រោយមត្តេយ្យ(PYR)។

## ២. ការបង់ប្រាក់សំរាប់មួយឆ្នាំ(គិតជាដុល្លាសហរដ្ឋអាមេរិក)

### ក. ថ្លៃបង្ហាត់បង្រៀន:

| ជំរើស | ការបង់ជាឆ្នាំ | ការបង់ជាឆមាស | | ការបង់ជាត្រីមាស | | | |
|---|---|---|---|---|---|---|---|
| កាលបរិច្ឆេទកំណត់ | ២៥ កក្កដា ២០១១ | ២៥ កក្កដា ២០១១ | ២ មករា ២០១២ | ២៥ កក្កដា ២០១១ | ៣ តុលា ២០១១ | ២ មករា ២០១២ | ១៥ មីនា ២០១២ |
| ថ្នាក់មត្តេយ្យទី១ | ៥,០៤០ | ២,៥៧០ | ២,៥៧០ | ១,៣១០ | ១,៣១០ | ១,៣១០ | ១,៣១០ |
| ថ្នាក់មត្តេយ្យទី២ | ៦,២៨០ | ៣,២០៣ | ៣,២០៣ | ១,៦៣៣ | ១,៦៣៣ | ១,៦៣៣ | ១,៦៣៣ |
| ថ្នាក់ PYR-ថ្នាក់ទី៥ | ១២,២២០ | ៦,២៣២ | ៦,២៣២ | ៣,១៧៧ | ៣,១៧៧ | ៣,១៧៧ | ៣,១៧៧ |
| ថ្នាកទី៦-ថ្នាក់ទី១០ | ១៤,៧៦០ | ៧,៥២៨ | ៧,៥២៨ | ៣,៨៣៨ | ៣,៨៣៨ | ៣,៨៣៨ | ៣,៨៣៨ |
| ថ្នាកទី១១-ថ្នាក់ទី១២ | ១៥,៩៨០ | ៨,១៥០ | ៨,១៥០ | ៤,១៥៥ | ៤,១៥៥ | ៤,១៥៥ | ៤,១៥៥ |

ការបង់ថ្លៃបង្ហាត់បង្រៀនមានបីជំរើសដែលអាចជ្រើសរើសបានតាមកាលបរិច្ឆេទកំណត់ដូចដែលបានបង្ហាញជូនក្នុងតារាងខាងលើ ការបូកបន្ថែមអត្រា២%និងអត្រា៤%នៃថ្លៃបង្ហាត់បង្រៀនជាឆ្នាំនឹងត្រូវបានយកមកអនុវត្តសំរាប់ការជ្រើសយករបៀបបង់ថ្លៃបង្ហាត់បង្រៀនជាឆមាស និងត្រីមាស។

## ២. ថ្លៃមូលធនៈ

| ជំរើសនៃការបង់ថ្លៃមូលធន | ជំរើសទី១ | ជំរើសទី២ | |
|---|---|---|---|
| កាលបរិច្ឆេទកំណត់ | **២៥ កក្កដា ២០១១** | **២៥ កក្កដា ២០១១** | **២ មករា ២០១២** |
| ថ្នាក់មត្តេយ្យទី១ និងទី២ | ៧៨០ | ៤៦៨ | ៤៦៨ |
| ថ្នាក់ PYR ដល់ថ្នាក់ទី១២ | ១,៨៨០ | ១,១២៨ | ១,១២៨ |

ជំរើសមួយក្នុងចំណោមជំរើសទាំងពីរសំរាប់ការបង់ថ្លៃមូលធនត្រូវបានដាក់ជូនដោយមានកាលបរិច្ឆេទកំណត់ដូចខាងលើ។ ការបង់ថ្លៃមូលធនតាមឆមាសត្រូវបូកបន្ថែមអត្រា២០%ទៅលើថ្លៃមូលធនប្រចាំឆ្នាំសរុប។

## ៣. តម្លៃសំរាប់សេវាកម្មសិក្សាបន្ថែមរបស់សិស្ស(គិតជាដុល្លាសហរដ្ឋអាមេរិក)

**តម្លៃសំរាប់ការសិក្សាបំប៉នភាសាអង់គ្លេសជាភាសាជាទី២/ភាសាបន្ថែម និងតម្លៃសំរាប់ការសិក្សាបំប៉នជាពិសេសត្រូវបង់តាមត្រីមាសដូចតទៅៈ**

| | | |
|---|---|---|
| **ថ្នាក់មត្តេយ្យទី១ ដល់ថ្នាក់ទី១** | ការសិក្សាបំប៉នភាសាអង់គ្លេសជាភាសាទី២/ការសិក្សាបំប៉នពិសេស | **មិនគិតថ្លៃ** |
| **ថ្នាក់ទី២ ដល់ថ្នាក់ទី៣** | ការសិក្សាបំប៉នភាសាអង់គ្លេសជាភាសាទី២ | ៤០០ |
| **ថ្នាក់ទី៤ ដល់ថ្នាក់ទី៥** | ការសិក្សាបំប៉នភាសាអង់គ្លេសជាភាសាទី២/ការសិក្សាបំប៉នពិសេស | ៤០០ |
| **ថ្នាក់ទី៦ ដល់ថ្នាក់ទី១២** | ការសិក្សាបំប៉នភាសាអង់គ្លេសជាភាសាទី២/ការសិក្សាបំប៉នពិសេសជំនួយដោយផ្នែក | ៤០០ |
| **ថ្នាក់ទី៦ ដល់ថ្នាក់ទី១២** | ការសិក្សាបំប៉នភាសាអង់គ្លេសជាភាសាទី២/ការសិក្សាបំប៉នពិសេសជំនួយពេញលេញ | **១,៣២៥** |

## ៤. ការបង់ថ្លៃផ្សេងៗ

សាលាបានព្យាយាមគ្រប់បែបយ៉ាងដើម្បីអោយរាល់ការបង់ថ្លៃផ្សេងៗទាំងឡាយត្រូវបានគិតបញ្ចូលទៅក្នុងការបង់ថ្លៃបង្ហាត់បង្រៀន។ ប៉ុន្តែការបង់ថ្លៃផ្សេងៗមួយចំនួនមានការប្រែប្រួលខ្លាំងរវាងកំរិតថ្នាក់ពីមួយទៅមួយ រឺពីមួយក្រុមទៅមួយក្រុម ដោយថ្លៃផ្សេងៗទាំងនោះត្រូវបានយកមកគិតផ្អែកទៅលើចំណាយរួមគ្នាជាមូលដ្ឋាន ហើយវិក័យប័ត្រសំរាប់ថ្លៃផ្សេងៗទាំងនោះត្រូវបានចេញជូនក្នុងអំឡុងឆ្នាំសិក្សា។ សូមទាក់ទងមកការិយាល័យហិរញ្ញវត្ថុ ប្រសិនបើត្រូវការព័ត៌មានអំពីការបង់ប្រាក់ រឺសំណងវិញពីនិយោជករបស់លោកអ្នក។ ការបង់ថ្លៃផ្សេងៗក្នុងពេលបច្ចុប្បន្នត្រូវបានធ្វើឡើងសំរាប់ទស្សនកិច្ចសិក្សា និងកម្មវិធីសិក្សាភាសាកំណើត។

## ៥. កាលកំណត់ និងល័ក្ខខ័ណ្ឌផ្សេងៗ

### ក. ការបញ្ចុះតម្លៃៈ

**ការចុះឈ្មោះយឺតពេលៈ** ប្រសិនបើការចុះឈ្មោះចូលរៀនត្រូវបានធ្វើឡើងក្រោយ៥០%នៃត្រីមាសមួយការចុះឈ្មោះនោះនឹងត្រូវទទួលបានការបញ្ចុះតម្លៃ៥០% នៃថ្លៃបង្ហាត់បង្រៀននៅក្នុងត្រីមាសនោះ។

**សំរាប់គ្រួសារៈ** សំរាប់គ្រួសារដែលមានកូនបីនាក់ រឺច្រើនចុះឈ្មោះចូលរៀន ការបញ្ចុះតម្លៃ៥%នៃថ្លៃបង្ហាត់បង្រៀននឹងត្រូវផ្តល់ជូនដល់កូនទីបីដែលចុះឈ្មោះចូលរៀន និង១០%សំរាប់កូនទីបួន និងកូនបន្តបន្ទាប់ក្នុងគ្រួសារដែលចុះឈ្មោះចូលរៀន គឺផ្តល់ជូនដល់កូនតូចជាងគេនៅក្នុងគ្រួសារតែប៉ុណ្ណោះ។

**ការចុះឈ្មោះបន្តៈ** សិស្សដែលបានបន្តការសិក្សានៅសាលាអន្តរជាតិក្រុងភ្នំពេញរយៈពេល៧ឆ្នាំជាប់គ្នា ដោយរាប់ចាប់ពីថ្នាក់ទី១ឡើងទៅនឹងទទួលបានការបញ្ចុះតម្លៃ១០%នៃថ្លៃមូលធនប្រចាំឆ្នាំ ចាប់ផ្តើមផ្តល់ជូននៅឆ្នាំទី៧នៃការចុះឈ្មោះចូលរៀន។

**ខ. បំរែបំរួលនៃគំរោងបង់ថ្លៃសាលាៈ** បំរែបំរួលនៃគំរោងបង់ថ្លៃសាលាអាចប្រព្រឹត្តទៅបាន ក្នុងករណីពិសេសដែលមានការអនុម័តជាលាយលក្ខ័អក្សរជាមុនដោយនាយកសាលា។ បំរែបំរួលនៃគំរោងបង់ថ្លៃសាលាត្រូវតែចុះហត្ថលេខា ដោយមាតាបិតា និងនាយកសាលាទុកជាមុន ដោយធ្វើសេចក្តីបរិយាយអំពីកាលបរិច្ឆេទកំណត់បង់ប្រាក់ និងមូលហេតុដែលបណ្តាលអោយមានការខកខានក្នុងការបង់ថ្លៃសាលា។

**គ. ការបង់ថ្លៃសាលាយឺតពេលៈ** ការបង់ថ្លៃសាលាយឺតពេលនឹងត្រូវបូកបន្ថែមអត្រា៤%ក្នុងមួយខែដោយបន្ថែមជារៀងរាល់ខែទៅលើថ្លៃសាលាដែលមិនបានបង់ទាន់ពេល រឺបន្ថែមទៅលើការបង់យឺតយ៉ាវដែលលើសពី១០ថ្ងៃរហូតទាល់តែបានបង់អស់។ សិស្សានុសិស្សដែលមិនបានបង់ថ្លៃសាលាលើសពី៣០ថ្ងៃអាចត្រូវបានដកហូតឯកសិទ្ធិចូលរៀនដោយសាលា ហើយនឹងមិនត្រូវបានធានាថានឹងរក្សាកៅអីជូននៅត្រីមាសបន្ទាប់នោះឡើយ ថ្វីបើថ្លៃសិក្សាត្រូវបានទូទាត់អស់នៅពេលនោះក្តី។ ឯកសារសាលារួមមានៈ របាយការណ៍ព្រឹត្តិប័ត្រពិន្ទុ និងវិញ្ញាបនប័ត្រផ្សេងៗនឹងត្រូវបានផ្តល់ជូនខណៈដែលថ្លៃសាលាដែលនៅជំពាក់ និងថ្លៃបន្ថែមលើការយឺតយ៉ាវត្រូវបានទូទាត់ចប់សព្វគ្រប់។ សិស្សអាចត្រូវបានដកចេញពីការប្រឡងក៏ដូចជាមិនទទួលបាននូវការវាយតម្លៃផ្សេងៗ ព្រមទាំងមិនអនុញ្ញាតអោយចុះឈ្មោះចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាឡើយ ប្រសិនបើការទូទាត់ថ្លៃសាលា និងថ្លៃបង់បន្ថែមនៅតែមិនដោះស្រាយ។ ការសិក្សានឹងត្រូវបានបញ្ឈប់ បើថ្លៃសាលាមិនត្រូវបានទូទាត់ទាល់តែសោះ ហើយរាល់បំណុលទាំងឡាយដែលហួសកំណត់ទូទាត់៣០ថ្ងៃនឹងត្រូវបានសាលាស្នើសុំអោយដោះស្រាយតាមរយៈភាគីស្របច្បាប់របស់សាលាសំរាប់ទារបំណុល រឺភាគីទីបីដោយរួមបញ្ចូលទៅក្នុងនោះនូវបំណុលឯបរទេសទាំងឡាយផងដែរ ខណៈដែលមាតាបិតាសិស្សបានដកកូនចេញពីសាលាអាស្រ័យដោយមានការផ្លាស់ប្តូរទីលំនៅ។

**ឃ. ការផ្លាស់ប្តូរក្នុងឆ្នាំសិក្សាៈ** ថ្លៃសិក្សាទាំងអស់អាចនឹងផ្លាស់ប្តូរក្នុងឆ្នាំសិក្សាដោយពុំបានជំរាបជូនជាមុនអាស្រ័យលើការប្រកាសសំរេចពីគណៈក្រុមប្រឹក្សាភិបាលសាលា។

**ង. វិធីសាស្ត្រក្នុងការបង់ប្រាក់ៈ** ថ្លៃសាលាអាចនឹងត្រូវធ្វើការទូទាត់តាមរយៈប្រព័ន្ធធនាគារ រឺតាមរយៈការផ្ទេរសាច់ប្រាក់គិតជាដុល្លាសហរដ្ឋអាមេរិកទៅគណនីសាលានៅឯធនាគារ រឺទូទាត់ជាមូលប្បទានប័ត្រដែលអាចដកសាច់ប្រាក់បាននៅធនាគារក្នុងប្រទេសកម្ពុជា និងធនាគារនៅឯសហរដ្ឋអាមេរិក។ រាល់បន្ទុកចំណាយទាំងឡាយសំរាប់សេវាកម្មធនាគារក្នុងការផ្ទេរសាច់ប្រាក់គឺជាបន្ទុករបស់អ្នកផ្ញើ(បញ្ជូន)។ ការទូទាត់ជាសាច់ប្រាក់សុទ្ធអាចនឹងត្រូវបានទទួលត្រឹមក៏រិតតិចជាងពីរពាន់ដុល្លាសហរដ្ឋអាមេរិក។

**ច. ប្រាក់សំណងនៅពេលឈប់រៀន:** សូមធ្វើការជូនដំណឹងជាលាយល័ក្ខអក្សរមកកាន់ការិយាល័យសាលា ដើម្បីទទួលបានបែបបទលាឈប់សំរាប់បំពេញ ដើម្បីបង្កភាពងាយស្រួលដល់សាលាក្នុងការរៀបចំជូនវិញនូវប្រាក់សំណងប្រសិនបើមាន។ បែបបទស្នើសុំយកប្រាក់សំណងវិញត្រូវធ្វើឡើងជាលាយល័ក្ខអក្សរជាចាំបាច់ ដើម្បីបញ្ជូនមកកាន់ការិយាល័យពាណិជ្ជកម្ម។ ថ្លៃបង្ហាត់បង្រៀនដែលសិស្សបានបង់រួចនឹងអាចទទួលបានសំណងវិញសំរាប់តែការពុំបានសិក្សាពេញមួយត្រីមាសប៉ុណ្ណោះ រីឯថ្លៃមូលធនដែលសិស្សបានបង់នឹងអាចផ្តល់ជូនវិញសំរាប់ការពុំបានសិក្សាពេញមួយឆមាស។ សំណងទៅលើថ្លៃបង្ហាត់បង្រៀននឹងមានគិតបន្ថែមអត្រា៤% និងគិតបន្ថែមអត្រា២០%ទៅលើថ្លៃមូលធនមុននឹងការទូទាត់សំណងទាំងនោះត្រូវបានផ្តល់ជូន។

**ឆ. ព័ត៌មានស្តីពីវិក័យប័ត្រ:** វិក័យប័ត្រសំរាប់ថ្លៃសិក្សានឹងត្រូវបានផ្ញើជូនអនុលោមទៅតាមព័ត៌មានស្តីពីជំរើសនៃការបង់ប្រាក់ និងអាស័យដ្ឋានសំរាប់ការបញ្ជូនវិក័យប័ត្រ ដែលបានបំពេញនៅលើបែបបទសំរាប់ចុះឈ្មោះចូលរៀន។ សំរាប់វិក័យប័ត្រទាំងឡាយដែលត្រូវផ្ញើទៅកាន់លំនៅដ្ឋាននឹងត្រូវបានផ្ញើតាមរយៈកូនតូចជាងគេបង្អស់ក្នុងគ្រួសារដែលបានចុះឈ្មោះចូលរៀន។ សូមផ្ញើលិខិតជាលាយល័ក្ខអក្សរមកកាន់ការិយាល័យពាណិជ្ជកម្ម ប្រសិនបើមានការផ្លាស់ប្តូរផ្សេងៗទាក់ទងទៅនឹងជំរើសបង់ប្រាក់ និងអាស័យដ្ឋានសំរាប់បញ្ជូនវិក័យប័ត្រ។

**ជ. ការទូទាត់បំណុល:** មាតាបិតា រឺអាណាព្យបាលសិស្សស្របច្បាប់ត្រូវចូលរួមទទួលខុសត្រូវទាំងស្រុងនូវកាតព្វកិច្ចក្នុងការបង់ថ្លៃសាលាតាមពេលកំណត់ និងការបង់ប្រាក់បន្ថែមផ្សេងៗប្រសិនបើមាន បើទោះជាថ្លៃសាលា និងថ្លៃបន្ថែមផ្សេងៗទាំងនោះជាបន្ទុកផ្ទាល់របស់មាតាបិតា រឺអាណាព្យាបាលក្តី រឺជាបន្ទុករបស់និយោជក រឺភាគទីបីណាមួយក្តី។

**ឈ. ព័ត៌មាន:** រាល់វិក័យប័ត្រ របាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងការឆ្លើយតបផ្សេងៗដែលទាក់ទងនឹងការបង់ប្រាក់គឺធ្វើឡើងជាភាសាអង់គ្លេស។ សូមទាក់ទងមកកាន់អាស័យដ្ឋានអ៊ីម៉ែល businessoffice@ispp.edu.kh ប្រសិនបើលោកអ្នកមានសំនួរ រឺសំណើរសំរាប់ជំនួយក្នុងការបកប្រែ។

*សាលាអន្តរជាតិក្រុងភ្នំពេញជាសាលាមិនរកប្រាក់ចំណេញ ដែលមានសមាគមមាតាបិតាសិស្សជាម្ចាស់ និងពឹងផ្អែកទាំងស្រុងទៅលើប្រាក់ចំណូលដែលបានមកពីថ្លៃសាលា ដើម្បីទ្រទ្រង់អោយមានធនធានគ្រប់គ្រាន់សំរាប់ប្រតិបត្តិការណ៍របស់សាលា។ វាជាល័ក្ខខ័ណ្ឌនៃការចុះឈ្មោះ និងបន្តចុះឈ្មោះចូលរៀននៃសិស្សានុសិស្សទាំងឡាយដែលមាតាបិតា រឺអាណាព្យាបាលស្របច្បាប់ត្រូវបានរំពឹងទុកថា មានលទ្ធភាពគ្រប់គ្រាន់ដើម្បីបង់ថ្លៃសាលាគ្រប់ចំនួន និងតាមកាលបរិច្ឆេទកំណត់។ មាតាបិតា និងអាណាព្យាបាលសិស្សស្របច្បាប់មានការទទួលខុសត្រូវ និងកាតព្វកិច្ចខ្ពស់ក្នុងការអាន និងប្រតិបត្តិតាមការណែនាំស្តីពីការបង់ថ្លៃសាលា និងបង់ប្រាក់បន្ថែមដូចដែលមាននៅក្នុងតារាងតម្លៃសិក្សា និងសៀវភៅព័ត៌មានសំរាប់មាតាបិតាសិស្ស។*

*សាលាអន្តរជាតិក្រុងភ្នំពេញទទួលស្គាល់ថា គ្រួសារនីមួយៗអាចនឹងមានបទពិសោធជួបផលវិបាកចំពោះចរាចរសាច់ប្រាក់ រឺវិបត្តិផ្នែកហិរញ្ញវត្ថុនៅក្នុងកាលៈទេសៈប្រែប្រួលណាមួយដែលនឹកស្មានមិនដល់ នៅក្នុងករណីនេះ លោកអ្នកត្រូវជូនដំណឹងជាបន្ទាន់មកកាន់ការិយាល័យពាណិជ្ជកម្ម ដើម្បីធ្វើការពិភាក្សាក្នុងការរៀបចំកែតម្រូវគំរោងបង់ថ្លៃសាលាសំរាប់រយៈពេលដ៏ខ្លីមួយ។*